# ស្ថានភាពអតិផរណានៅខែកក្កដា ឆ្នាំ២០១៧

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែកក្កដា ឆ្នាំ២០១៧ បានកើនឡើងក្នុងអត្រា**០,៣%** ធៀបនឹងខែមុន និងកើនឡើង**២,៣%** បើធៀបនឹង១ឆ្នាំ។

តាមការសង្កេត សន្ទស្សន៍ថ្លៃនៃក្រុមទំនិញភាគច្រើនបានកើនឡើងធៀបនឹងខែមុន ក្នុងនោះសន្ទស្សន៍ថ្លៃអាហារបានកើនឡើង០,៤% ដោយសារកំណើនថ្លៃសាច់ បន្លែនិងផ្លែឈើ, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើងបានកើនឡើង០,៧% ដោយសារកំណើននៃថ្លៃវត្ថុធាតុដើមសម្រាប់ផលិតសម្លៀកបំពាក់, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈបានកើនឡើង០,៤% មកពីកំណើនថ្លៃការផ្គត់ផ្គង់ទឹកនិងសេវាផ្សេងៗសម្រាប់លំនៅដ្ឋាន, សន្ទស្សន៍ថ្លៃសុខាភិបាលបានកើនឡើង០,៣% និងសន្ទស្សន៍ថ្លៃកំសាន្តនិងវប្បធម៌បានកើនឡើង០,៤%។

បើធៀបនឹង១ឆ្នាំមុន សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនបានកើនឡើងគួរឲ្យកត់សម្គាល់ ដូចជាសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន បានកើនឡើង៦,៥% អាហារនិងភេសជ្ជៈគ្មានជាតិស្រវឹងកើនឡើង២,៧% សម្លៀកបំពាក់កើនឡើង២,៥% និងការដឹកជញ្ជូនកើនឡើង២,៩%។ តាមរយៈការធ្វើចំណោលគិតត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ១,៨% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ(year average)អាចមានអត្រា ២,៩%។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **0.3** | **2.3** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | 0.4 | 2.7 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | 0.2 | 1.5 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.7 | 2.5 |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 0.4 | -0.8 |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -0.1 | 1.4 |
| ៦-សុខាភិបាល | 0.3 | 1.0 |
| ៧-ការដឹកជញ្ជូន | 0.0 | 2.9 |
| ៨-គមនាគមន៍ | 0.1 | -0.1 |
| ៩-ការកំសាន្ត និងវប្បធម៌ | 0.4 | 2.0 |
| ១០-ការសិក្សា | 0.0 | 0.0 |
| ១១-ភោជនីយដ្ឋាន | 0.0 | 6.5 |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | 0.0 | -0.1 |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (គិតជា %) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន | | | ធៀបនឹង១ឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | ឧសភា | មិថុនា | កក្កដា | ឧសភា | មិថុនា | កក្កដា |
| អង្ករ | -0.1 | 0.7 | 0.2 | 1.9 | 2.4 | 2.2 |
| សាច់គោ | -0.2 | -0.3 | 0.3 | 3.3 | 1.8 | 2.0 |
| សាច់មាន់ | -1.8 | 0.7 | 0.4 | 1.2 | 1.6 | 1.9 |
| សាច់ទា | -1.0 | -0.4 | 0.9 | -1.0 | -1.2 | 0.0 |
| សាច់ជ្រូក | -1.2 | -0.1 | 0.1 | 2.2 | 1.4 | 1.2 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | -0.4 | 0.8 | 0.2 | 5.4 | 5.4 | 4.9 |
| ក្នុងនោះត្រីស្រស់ | -0.3 | 1.1 | 0.2 | 5.6 | 6.0 | 5.4 |
| ផ្លែឈើ | -1.0 | 0.4 | 0.9 | 0.9 | 0.6 | 1.8 |
| ផ្លែឈើស្រស់ | -1.5 | 0.0 | 1.2 | 0.7 | 0.2 | 1.8 |
| បន្លែ | -1.3 | -1.8 | 1.7 | 3.4 | 1.1 | 3.2 |
| បន្លែជាស្លឹក | -1.5 | -2.1 | 2.5 | 2.7 | 0.3 | 4.0 |
| បន្លែជាផ្លែ | -2.1 | -2.7 | 1.2 | 2.9 | -1.4 | 0.2 |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាប្រចាំឆ្នាំ (គិតជា %) | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | | | | | | | ២០១៧ | | | | | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា |
| ប្រទេសកម្ពុជា | 3.0 | 2.3 | 2.0 | 2.8 | 3.2 | 3.3 | 3.0 | 4.4 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 |
| ប្រទេសវៀតណាម | 0.8 | 1.3 | 1.7 | 1.9 | 2.3 | 2.4 | 2.4 | 5.2 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 |
| ប្រទេសថៃ | -0.5 | -0.5 | -0.5 | 0.1 | 0.5 | 0.4 | 0.1 | 1.6 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 |
| ប្រទេសម៉ាឡេស៊ី | 3.5 | 4.2 | 2.6 | 2.1 | 2.1 | 1.6 | 1.1 | 3.2 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 |
| ប្រទេសឥណ្ឌូនេស៊ី | 4.1 | 4.4 | 4.5 | 3.6 | 3.3 | 3.5 | 3.2 | 3.5 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 |
| ប្រទេសហ្វីលីពីន | 1.4 | 0.9 | 1.1 | 1.1 | 1.6 | 1.9 | 1.9 | 2.7 | 3.3 | 3.4 | 3.4 | 3.1 | 2.7 | 2.8 |
| ប្រទេសចិន | 1.8 | 2.3 | 2.3 | 2.3 | 2.0 | 1.9 | 1.8 | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 |
| ប្រទេសកូរ៉េខាងត្បូង | 0.8 | 1.2 | 0.97 | 1.0 | 0.8 | 0.8 | 0.8 | 2.0 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 |
| ប្រទេសជប៉ុន | -0.1 | 0.3 | 0.0 | -0.3 | -0.5 | -0.4 | -0.4 | 0.4 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត ពីគេហទំព័រ http://www.tradingeconomics.com;

## កំណត់សម្គាល់

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

*រៀបចំនិងធ្វើចំណោលដោយ*

*នាយកដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*